ការចេញផ្សាយលើកទី ១ ខែមិថុនាឆ្នាំ២០១៨

មាតិកា

១. សេចក្តីអធិប្បាយគម្រោង
២. អំពីក្រុមការងារគម្រោង
៣. ពិធីប្រកាសបើកគម្រោងជាផ្លូវការ
៤. ការផលិតឯកសារណែនាំ
៥. ការប្រជុំប្រឹក្សាយោបល់
៦. ម្ចាស់ជំនួយរបស់គម្រោង
៧. អាសយដ្ឋានទំនាក់ទំនង

TIGER
លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និង រៀន
TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

១. សេចក្តីអធិប្បាយគម្រោង "លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន"

គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន មានគោលបំណងប្រែក្លាយវិទ្យាស្ថានគរុកោសល្យ សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិចំនួន៤០ នៅក្នុងខេត្តបាត់ដំបង**ឱ្យក្លាយគ្រឹះស្ថានគំរូដែលមានការឆ្លើយតបយ៉ាងប្រសើរលើបញ្ហាយេនឌ័រ** ដើម្បីធានាថាសិស្សានុសិស្សនៅសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិត្រូវបានការពារពីអំពើហិង្សាផ្អែកយេនឌ័រ និងផ្តល់លទ្ធភាពឱ្យពួកគេបានចូលរួមដោយសមធម៌ក្នុងគ្រប់សកម្មភាពនៃជីវិតទាំងក្នុងសាលារៀន និងនៅតាមផ្ទះ។ គម្រោងនឹងសហការជាមួយ៖

- គណៈគ្រប់គ្រង និងគ្រូឧទ្ទេសដើម្បីធ្វើឱ្យវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបងក្លាយជាគ្រឹះស្ថានគំរូក្នុងការឆ្លើយតបនឹងបញ្ហាយេនឌ័រ និងបណ្តុះបណ្តាលគរុនិស្សិតអំពីវិធីបង្រៀនដោយគ្មានការរើសអើងផ្អែកយេនឌ័រ
- គណៈគ្រប់គ្រង គ្រូបង្រៀន និងគណៈកម្មការទ្រទ្រង់សាលារៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិចំនួន៤០ ដើម្បីធ្វើឱ្យសាលារៀនរបស់ពួកគាត់មានសុវត្ថភាព និងបរិយាកាសល្អប្រសើរសម្រាប់អ្នកសិក្សាទាំងអស់
- អង្គការ និងសមាគមចំនួន៥ ដែលគាំទ្រវិស័យអប់រំក្នុងខេត្តបាត់ដំបង ដើម្បីបំប៉នសមត្ថភាពបុគ្គលិករបស់ខ្លួនក្នុងការគាំទ្រដល់សាលារៀនគោលដៅឱ្យក្លាយជាសាលារៀនដែលមានការឆ្លើយតបនឹងសមភាពយេនឌ័រ
- មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ដើម្បីពង្រឹងការយល់ដឹងអំពីយេនឌ័រ និងជួយបង្កើតបរិយាកាសសមភាពយេនឌ័រចំពោះកូនៗរបស់ពួកគាត់។

២. អំពីក្រុមការងារគម្រោង

គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀនមានក្រុមការងារដែលមានជំនាញផ្នែកយេនឌ័រ និងអប់រំពីអង្គការមួយចំនួនដូចខាងក្រោម៖

- អង្គការ VVOB
- អង្គការពុទ្ធិកុមារ (PKO)
- អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE)

បច្ចុប្បន្នក្រុមការងារគម្រោងកំពុងផលិតឯកសារណែនាំ ស្តីពីការអប់រំដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ ពួកយើងនឹងចាប់ផ្តើមបំប៉នក្រុមគោលដៅនៅក្នុងពេលឆាប់ៗនេះ ក្រុមគោលដៅដំបូងគេគឺ គណៈគ្រប់គ្រងវិទ្យាស្ថានគរុកោសល្យ បុគ្គលិកអង្គការ និងសមាគមដែលគាំទ្រវិស័យអប់រំក្នុងខេត្ត។

ក្រុមការងាររបស់យើងរាប់ពីឆ្វេងទៅស្តាំ៖
ហុង ម៉ាទីន (VVOB) រឿន សត្យា (GADC)
សយ សំផុន (VVOB) ឈួន ចំរើន (PKO)
ស៊ុន ម៉ាលី (VVOB) និង អ៊ុក សុធីរ៉ា (KAPE)។

"យើងត្រូវចូលរួមលុបបំបាត់ផ្នត់គំនិតបុរាណដែលមានភាពលម្អៀងយេនឌ័រនៅតាមសាលារៀន និងសហគមន៍ ដើម្បីឱ្យសង្គមរបស់យើងគ្មានការរើសអើង និងអំពើហិង្សាផ្អែកយេនឌ័រ។"

អ្នកស្រី អ៊ុក សុធីរ៉ា, អ្នកឯកទេសផ្នែកយេនឌ័ររបស់អង្គការ KAPE

៣. ពិធីប្រកាសបើកគម្រោងជាផ្លូវការ

នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៨ យើងបានប្រារព្ធពិធីប្រកាសបើកគម្រោង TIGER ជាផ្លូវការ។ កម្មវិធីបើកគម្រោងនេះមានអ្នកចូលរួមសរុបចំនួន ៩៧ នាក់ (ស្រី ៥៥ នាក់) ដែលជាតំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី តំណាងស្នងការនគរបាលខេត្ត ប្រធានក្រុមការងារគាំទ្រវិស័យអប់រំថ្នាក់ខេត្ត អង្គការ និងសមាគមដែលគាំទ្រវិស័យអប់រំ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតា និងអ្នកអាណាព្យាបាល។ ឯកឧត្ដម អ៊ុង បូរាត អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើពិធីប្រកាសបើកដំណើរការគម្រោង និងមានប្រសាសន៍ថា "កុមារមិនត្រឹមតែរៀននៅក្នុងថ្នាក់បណ្ដោះទេ គឺពួកគេអាចរៀននៅក្រៅសាលាដែរ" ដូច្នេះគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ មាតាបិតា និងសហគមន៍ត្រូវបង្ហាញតួនាទីគំរូក្នុងការលើកកម្ពស់សមភាពយេនឌ័រទាំងក្នុងសាលារៀន និងនៅតាមផ្ទះ។

៤. ការផលិតឯកសារណែនាំ

ឯកសារណែនាំនឹងផ្ដល់ឱ្យគណៈគ្រប់គ្រងសាលារៀននូវផែនទីបង្ហាញផ្លូវមួយក្នុងការសម្របសម្រួលសកម្មភាពអភិវឌ្ឍសមត្ថភាពក្នុងការប្រែក្លាយសាលារៀនឱ្យឆ្លើយតបនឹងសមភាពយេនឌ័រ និងការទប់ស្កាត់អំពើហិង្សាផ្អែកយេនឌ័រតាមសាលារៀន។

ឯកសារណែនាំនេះនឹងផ្ដល់នូវវិធីសាស្ត្រ និងឧបករណ៍អនុវត្តជាក់ស្ដែងដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលារៀន ដើម្បីប្រែក្លាយសាលារៀនឱ្យមានការឆ្លើយតបយ៉ាងប្រសើរលើបញ្ហាយេនឌ័រ។

ឯកសារណែនាំនេះមានមេរៀនចំនួន១៧ ដែលត្រូវបានបែកចែកជា ៣ជំពូកធំៗ៖

- ជំពូក១: ការយល់ដឹងជាមូលដ្ឋានអំពីយេនឌ័រ
- ជំពូក២: ភាពជាអ្នកដឹកនាំសាលារៀនដែលឆ្លើយតបនឹងយេនឌ័រ
- ជំពូក៣: គរុកោសល្យនៃការឆ្លើយតបនឹងយេនឌ័រ

៥. ការប្រជុំប្រឹក្សាយោបល់

ក្រុមការងារសម្រាប់ផ្ដល់ប្រឹក្សាយោបល់លើការកសាងឯកសារណែនាំមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ និងអង្គការដៃគូ ដែលមានជំនាញផ្នែកអប់រំ និងយេនឌ័រ។ ក្រុមការងារនេះមានតួនាទីក្នុងការផ្ដល់ជាធាតុចូល និងអនុសាសន៍ផ្សេងៗក្នុងការកសាងឯកសារណែនាំស្ដីពីការអប់រំដែលឆ្លើយបតនឹងសមភាពយេនឌ័រ ដើម្បីឱ្យស្របតាមគោលនយោបាយរបស់ក្រសួង ការស្រាវជ្រាវថ្មីៗ សកម្មភាព និងគម្រោង ផ្សេងៗទៀត។ ក្រុមការងារនេះក៏ជាអ្នកធានានូវគុណភាពឯកសារណែនាំនេះផងដែរ។ ចាប់ពីខែកុម្ភៈដល់ ខែឧសភា ឆ្នាំ ២០១៨ មានការប្រជុំប្រឹក្សាយោបល់ប្រកបដោយផ្លែផ្កាចំនួនបួនលើកហើយ ជាលទ្ធផលក្រុមការងារបានពិនិត្យ និងកែលម្អបាន ១៣ មេរៀន លើ១៧មេរៀន។

៦. ម្ចាស់ជំនួយរបស់គម្រោង

EUROPEAN UNION

Belgium
partner in development

Flanders
State of the Art

អាសយដ្ឋាន៖ ផ្ទះលេខ B-53, ភូមិកម្មករ, សង្កាត់ស្វាយប៉ោ,
ក្រុង-ខេត្តបាត់ដំបង, ប្រទេសកម្ពុជា។
គេហទំព័រ៖ www.cambodia.vvob.be/tiger
ស្វែងរកពួកយើងតាមរយៈហ្វេកប៊ុក៖ @vvobcambodia, @kapeaction,
@genderissue, @pkocambodia.org

ព្រឹត្តិប័ត្រព័ត៌មាននេះ ផលិតដោយមានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។
ខ្លឹមសារដែលមានក្នុងព្រឹត្តិប័ត្រនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់
អង្គការ VVOB, GADC, PKO និង KAPE ហើយវាមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់
សហភាពអឺរ៉ុបឡើយ។ រដ្ឋាភិបាលបែលហ្ស៊ិកមិនអាចទទួលខុសត្រូវចំពោះ
ខ្លឹមសាររបស់ព្រឹត្តិប័ត្រព័ត៌មាននេះដែរ។